# ឯការាជ្យភាពតុលាការ

**មេធាវី សុក សំអឿន**
ប្រធានក្រុមអ្នកច្បាប់ **អមរិន្ទ**
សាស្ត្រាចារ្យច្បាប់

# ដូចម្តេចហៅថាតុលាការឯករាជ្យ?




ដែលហៅថាតុលាការឯករាជ្យ មិនមែនមានន័យថាលុះត្រាតែតុលាការត្រូវដាក់ទីតាំងនៅលើកកោះឯការម្នាក់ឯងនោះទេ!

# ដូចម្តេចហៅថាតុលាការឯករាជ្យ?




- តុលាការឯករាជ្យ គឺសំដៅទៅលើ នៅពេលដែលចៅក្រមធ្វើសេចក្តីសម្រេចចិត្ត ចៅក្រមសម្រេចចិត្ត ដោយមិនលុះនូវអគតិទាំងបួន៖
  - ភ័យោគតិ
  - ឆន្ទាគតិ
  - មោហាគតិ និង
  - ទោសាគតិ។

# ដូចម្តេចហៅថាតុលាការឯករាជ្យ?




- បើពេលកាត់ក្តី ចៅក្រមខ្លាច ឬ បារម្ភ
  - ខ្លាចគេដកតំណែង
  - ខ្លាចគេដាក់វិន័យ
  - ខ្លាចគេព្យាបាទ
  - ខ្លាចគេមិនតម្លើងឋានៈ
  - ខ្លាចប្រពន្ធខឹង
- គឺមានន័យថា ចៅក្រមនោះកំពុងតែរង នូវ **ភ័យាគតិ**។

# ដូចម្តេចហៅថាតុលាការឯករាជ្យ?




- បើពេលកាត់ក្តី ចៅក្រម កាត់ដោយ
  - យល់ថាជាញាតិរបស់ខ្លួន
  - យល់ថាជាសមាជិកបក្សជាមួយគ្នា
  - ស៊ីសំណូកពីភាគីម្ខាង
- គឺមានន័យថា ចៅក្រមនោះកំពុងតែកាត់ក្តីវង្វេង **ឆន្ទាគតិ**។

# ដូចម្ដេចហៅថាតុលាការឯករាជ្យ?




- បើពេលកាត់ក្ដី ចៅក្រម កាត់ដោយ
  - ខឹង ឬ ស្អប់ភាគីណាមួយ
  - រើសអើងជាតិពន្ធ
  - រើសអើងគណបក្សនយោបាយ
  - រើសអើងភេទ
- គឺមានន័យថា ចៅក្រមនោះកំពុងតែកាត់ក្ដីវងនូវ **ពោសាគតិ។**

# ដូចម្តេចហៅថាតុលាការឯករាជ្យ?




- បើពេលកាត់ក្តី ចៅក្រម កាត់ដោយ
  - ❋ ខ្វល់យល់ដឹងពីច្បាប់
  - ❋ ផ្អែកតែទៅលើភស្តុតាងដែលមិនពិត
  - ❋ កង្វះភស្តុតាង កង្វះការពិត
- គឺមានន័យថា ចៅក្រមនោះកំពុងតែកាត់ក្តីវងនូវ មោហាគតិ។

# ឯករាជ្យបុគ្គល និង ឯករាជ្យស្ថាប័ន

- បុគ្គលចៅក្រម មិនអាចនឹងធ្វើការងារដោយឯករាជ្យបានឡើយ ប្រសិនបើស្ថាប័នតុលាការមិនអាចឯករាជ្យបាននោះ។
- ព្រោះថាប្រសិនបើ ស្ថាប័នគ្រប់គ្រងចៅក្រមស្ថិតនៅក្រោមឥទ្ធិពលរបស់អំណាចនីតិប្រតិបត្តិនោះ ចៅក្រម ក៏នឹងត្រូវស្ថិតនៅក្រោមឥទ្ធិពលរបស់អំណាចនីតិប្រតិបត្តិផងដែរ។
- ដូចនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែឯករាជ្យ ផងដែរ ប្រសិនបើចង់ឲ្យតុលាការឯករាជ្យ។

# ឯករាជ្យបុគ្គល និង ឯករាជ្យស្ថាប័ន

- បុគ្គលចៅក្រម មិនអាចនឹងធ្វើការងារដោយឯករាជ្យបានឡើយ ប្រសិនបើស្ថាប័នតុលាការមិនអាចឯករាជ្យបាននោះ។
- ព្រោះថាប្រសិនបើ ស្ថាប័នគ្រប់គ្រងចៅក្រមស្ថិតនៅក្រោមឥទ្ធិពលរបស់អំណាចនីតិប្រតិបត្តិនោះ ចៅក្រម ក៏នឹងត្រូវស្ថិតនៅក្រោមឥទ្ធិពលរបស់អំណាចនីតិប្រតិបត្តិផងដែរ។
- ដូចនេះ ឧត្តមក្រុមប្រឹក្សាដែនអង្គចៅក្រមត្រូវតែឯករាជ្យ ផងដែរ ប្រសិនបើចង់ឲ្យតុលាការឯករាជ្យ។

# ធ្វើយ៉ាងណាឲ្យស្ថាប័នឯករាជ្យ?

- បុគ្គលអ្នកដឹកនាំស្ថាប័នោះត្រូវតែឯករាជ្យ
- ស្ថាប័ននោះត្រូវតែមានសិទ្ធិគ្រប់គ្រង និង ចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួន។
- ត្រូវមានថវិការ និង មធ្យោបាយប្រតិបត្តិការគ្រប់គ្រាន់។
- សមាជិកឧត្តមក្រុមប្រឹក្សាត្រូវតែជាមនុស្សឯករាជ្យ មិនក្រោមឥទ្ធិពលស្ថាប័នផ្សេងទៀត។
- ឧត្តម ត្រូវតែមានសិទ្ធិគ្រប់គ្រង និង ចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនដោយខ្លួនឯង។
- ឧត្តមត្រូវតែមានសិទ្ធិរៀបគំរោងថវិការ ដើម្បីសុំកញ្ចប់ថវិការពីថវិការជាតិ។

# គោលការណ៍ពាក់ព័ន្ធនឹងតុលាការ

- គោលការណ៍បែងចែកអំណាច
- តុលាការត្រូវតែឯករាជ្យ
- តុលាការត្រូវតែមានសមត្ថកិច្ច ហើយចៅក្រមត្រូវតែមានសមត្ថភាព
- ត្រូវមាននីតិវិធីដែលធានាដល់សិទ្ធិរបស់ភាគី ហើយតុលាការត្រូវតែអនុវត្តនីតិវិធីនោះដោយខ្ជាប់ខ្ជួន។

# គោលការណ៍បែងចែកអំណាច

- គោលការណ៍នេះបានកំណត់ដោយរដ្ឋធម្មនុញ្ញ តាមមាត្រា ៥១ ថ្មី ដែលបានចែងថា៖ អំណាចបែងចែកដាច់ពីគ្នា រវាង អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។
- បើអំណាចទាំងបី គ្មានការបែងចែកច្បាស់លាស់ របបគ្រប់គ្រងនឹងឈានទៅរកការប្រមូលផ្តុំលើមនុស្សមួយក្រុម (ដូចជារបបប៉ុលពត) ឬនៅលើ មនុស្សតែម្នាក់ (របបសក្តិភូមិ ឬ អំណាចផ្តាច់ការ)។

# គោលការណ៍បែងចែកអំណាច

- តុលាការនឹងបាត់បង់ **ឯករាជ្យភាពរបស់ខ្លួន** បាត់បង់ការគាំ ទ្រ និង គោរពពីប្រជារាស្ត្រ ហើយឈានទៅរកការបាត់បង់ជំនឿ និង គាំទ្ររដ្ឋាភិបាល។
- ដូចនេះ ប្រសិនបើ ធ្វើច្បាប់ឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាអ្នកនយោបាយនៃអំណាចនីតិប្រតិបត្តិ មានអំណាចច្រើន ឬ មានឥទ្ធិពលខ្លាំងលើ តុលាការ នោះគឺជាការបំពានទៅនឹង គោលការណ៍បែងចែកអំណាច និង ជាការរំលោភទៅលើ **រដ្ឋធម្មនុញ្ញ**។

# សមាជិកាឧត្តមក្រុមប្រឹក្សា

| ច្បាប់បច្ចុប្បន្ន | សេចក្តីព្រាង |
| --- | --- |
| ១. ព្រះមហាក្សត្រ ព្រះប្រធាន | ១. ព្រះមហាក្សត្រ ព្រះប្រធាន |
| ២. រដ្ឋមន្ត្រីក្រ.យុត្តិធម៌ | ២. រដ្ឋមន្ត្រីក្រ.យុត្តិធម៌ |
| ៣. ប្រធានតុលាការកំពូល | ៣. ប្រធានតុលាការកំពូល |
| ៤. អគ្គព្រះរាជអាជ្ញាកំពូល | ៤. អគ្គព្រះរាជអាជ្ញាកំពូល |
| ៥. ចាងហ្វាងសាលាឧទ្ធរណ៍ | ៥. អ្នកច្បាប់ រើសដោយរដ្ឋសភា ១រូប |
| ៦.អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ | ៦. អ្នកច្បាប់ រើសដោយព្រឹទ្ធសភា ១ រូប |
| ៧. ចៅក្រម/ព្រះរាជ ដោយបោះឆ្នោត | ៧. ចៅក្រមជាន់ខ្ពស់/ព្រះរាជធ្វើការនៅក្រ.យុត្តិ ដោយបោះឆ្នោតដោយ ចៅ/ព្រះ |
| ៨. ចៅក្រម/ព្រះរាជ ដោយបោះឆ្នោត | ៨. ចៅក្រមសាលាដំបូង ដោយចៅក្រមទូទៅ |
| ៩. ចៅក្រម/ព្រះរាជ ដោយបោះឆ្នោត។ | ៩. ព្រះរាជអាជ្ញាសាលាដំបូង ដោយព្រះរាជ។ |
| (តែការអនុវត្ត ៧៨៩ ដោយតែងតាំង) | |

# ហិរញ្ញវត្ថុឧត្តមក្រុមប្រឹក្សាក្នុងសេចក្តីព្រាង

មាត្រា ១៤៖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានកញ្ចប់ថវិការរបស់ខ្លួន ដែលផ្តត់ផ្គង់ដោយថវិកាជាតិ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាណាប័កផ្ទេរសិទ្ធិដោយពេញច្បាប់ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

- រដ្ឋធម្មនុញ្ញបានប្រគល់តួនាទីដល់ព្រះមហាក្សត្រក្នុងការធានាដល់ឯករាជ្យភាពរបស់តុលាការ និង ភាពយុត្តិធម៌ក្នុងសង្គម ហើយបានប្រគល់តួនាទីទៅឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ដែលជាអ្នកជួយដល់ព្រះមហាក្សត្រក្នុងកិច្ចការនេះ។

# ហិរញ្ញវត្ថុឧត្តមក្រុមប្រឹក្សាក្នុងសេចក្តីព្រាង

មាត្រា ១៤៖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានកញ្ចប់ថវិការបស់ខ្លួន ដែលផ្តត់ផ្គង់ដោយថវិកាជាតិ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាណាប័កផ្ទេរសិទ្ធិដោយពេញច្បាប់ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

- យោងតាមមាត្រាខាងលើ រដ្ឋមន្ត្រីក្រ.យុត្តិធម៌ ឬ អំណាចនីតិប្រតិបត្តិគ្រប់គ្រង និង ចាត់ចែងហិរញ្ញវត្ថុរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- មានន័យថា ឯករាជ្យភាពនៃអំណាចតុលាការទទួលការប៉ះពាល់មួយផ្នែកធំ។

# អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សា

- យោងតាមច្បាប់បច្ចុប្បន្ន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានលេខាធិការដ្ឋានមួយ សម្រាប់តែជួយកិច្ចការរបស់ឧត្តមក្រុមប្រឹក្សា តែមិនសូវមានឥទ្ធិពល និង មានអំណាចអ្វីទេ ។
- នៅឆ្នាំ ២០០០ សង្គមស៊ីវិលបានស្នើរឲ្យវិសោធនកម្មច្បាប់ដោយ តម្លើងតួនាទី លេខាធិការដ្ឋាននេះឲ្យទៅជាំ អគ្គលេខាធិការដ្ឋាន និង បង្កើតឲ្យមាននាយកដ្ឋានក្រោមបង្គាប់ ដើម្បីដំណើការឲ្យមានប្រសិទ្ធិភាព ។
- នៅឆ្នាំ ២០០២ រដ្ឋាភិបាលមិនបានបានវិសោធនកម្មច្បាប់ទេ តែបែរជានាយករដ្ឋមន្ត្រីបង្កើតអគ្គលេខាធិការដ្ឋានឲ្យឧត្តម ជំនួសកែច្បាប់ ។

# អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សា

- ប៉ុន្តែនៅពេលនោះ សមាជិកឧត្តមភាគច្រើន ច្រើនមកពីគណបក្សប្រជាជន ចំណែករដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- នៅឆ្នាំ ២០០៥ តំណែងរដ្ឋមន្ត្រី ត្រូវបានមកពីគណបក្សប្រជាជន។
- នៅឆ្នាំ ២០០៥ ដដែល នាយករដ្ឋមន្ត្រីបានលប់អគ្គលេធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
- នៅក្នុងសេចក្តីព្រាងច្បាប់ មាត្រា ៨ បានចែងថា៖ “ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានអគ្គលេខាធិការដ្ឋានមួយស្ថិតនៅក្រោមរដ្ឋបាលកណ្តាលនៃក្រ.យុត្តិធម៌”។

# អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- ចំពោះអ្នកគ្រប់គ្រងអគ្គលេខាធិការដ្ឋាននេះ មាត្រានេះបានចែងថា៖
- អគ្គលេខាធិការ និង អគ្គលេខាធិការរង នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម”។
- ដូចនេះ គឺមានន័យថា អគ្គលេខាធិការដ្ឋាននេះ គឺជាស្ថាប័នដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រ.យុត្តិធម៌។
- ពោលគឺ ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រ.យុត្តិធម៌ ឬ អំណាចនីតិប្រតិបត្តិ។

# ការដាក់វិន័យ

- នៅក្នុងច្បាប់បច្ចុប្បន្ន ការដាក់វិន័យ គឺធ្វើដោយក្រុមប្រឹក្សាវិន័យ ក្នុងករណីមានការតវ៉ាពីសាមីខ្លួន ត្រូវបញ្ជូនទៅសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាំងមូលតែម្តង ដែលក្នុងនោះត្រូវមានវត្តមានដោយព្រះប្រធាន ឬ អ្នកតំណាង។
- ក្នុងសេចក្តីព្រាងច្បាប់ ការដាក់វិន័យ គឺធ្វើដោយក្នុងនាមឧត្តមក្រុមប្រឹក្សាទាំងមូល ពោលគឺ បិទផ្លូវតវ៉ា។
- មានន័យថា ការដាក់វិន័យចៅក្រម ឬ ព្រះរាជអាជ្ញា គឺមិនមានសិទ្ធិឧទ្ធរណ៍នោះទេ។

# ក្រុមអធិការកិច្ច

- នៅក្នុងសេចក្តីព្រាង ក្រុមអធិការកិច្ចមួយត្រូវបង្កើតឡើងនៅក្រោមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តែដាក់ផ្លាកថា ជាក្រុមអធិការកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
- ការស៊ើបអង្កេតធ្វើឡើងដោយក្រ.យុត្តិធម៌ អាចនឹងធ្វើបាន តែមិនមែនក្នុងនាមរបស់ឧត្តមក្រុមប្រឹក្សានោះទេ ការស៊ើបអង្កេតដោយឧត្តម និងកាត់ក្តីដោយឧត្តម អាចនឹងនាំឲ្យមានចម្ងល់ពីភាពឯករាជ្យនៃស្ថាប័ននេះ។

# អរគុណ

Proud to be Khmer